# *សិលាចារឹកកំពូលតានន់ (K.1236)*

*កំពូលតានន់ ឬហៅម្យ៉ាងទៀតថាដុបតាញៀន មានទីតាំងស្ថិតនៅតំបន់ភ្នំបាយ៉ង់ ភូមិត្រពាំងស្រង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង្ស ខេត្តតាកែវ។ សិលាចារឹកនេះ រកឃើញដោយចៃដន្យដោយប្រជាពលរដ្ឋនៅតំបន់នោះ ក្នុងពេលកាប់គាស់ភ្ជួរដីដាំដំណាំ ហើយក៏យកទៅរក្សាទុកបញ្ឈរនៅខាងមុខប្រាសាទកំពូលតានន់ ឬដុបតាញៀនរហូតមក។ ក្រោយមក គេបានយកទៅជួសជុលនៅសារមន្ទីរជាតិកម្ពុជា និងចុងក្រោយយកទៅរក្សាទុកនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ រហូតមកទល់បច្ចុប្បន្ន។ កន្លងមក លោក វង់ សុធារ៉ា ធ្លាប់បានសិក្សាសិលាចារឹកនេះម្តងរួចមកហើយ ប៉ុន្តែ លោកបានសិក្សានិងបកប្រែតែអត្ថបទជាភាសាខ្មែរចំនួន ៩ បន្ទាត់ចុងក្រោយតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ នៅក្នុងអត្ថបទនេះយើងនឹងបង្ហាញអំពីផ្នែកសំស្ក្រឹតចំនួន ២១ បន្ទាត់ នៃសិលាចារឹកកំពូលតានន់នេះ។ តើអត្ថបទសំស្ក្រឹតទាំងនេះមានខ្លឹមសារ និងអត្ថន័យដូចម្តេចខ្លះ?*

*គួរឱ្យកត់សម្គាល់ សិលាចារឹកនេះបានផ្តល់កាលបរិច្ឆេទដាក់លាក់នៅក្នុងមហាសករាជឆ្នាំ ៦៨៥ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ៧៦៣ ដែលរៀបរាប់អំពីព្រឹត្តិការណ៍របស់ព្រះបាទជ័យវម៌្ម។ ព្រះនាម "ជ័យវម៌្ម" នៅក្នុងសិលាចារឹកនេះ គឺប្រាកដជាព្រះបាទជ័យវរ្ម័នទី២ ដែលអ្នកស្រាវជ្រាវយល់ថាជាស្ថាបនិកដំបូងនៃសម័យអង្គរ ពោល គឺមិនអាចជាព្រះបាទជ័យវរ្ម័នទី១ បានឡើយ ព្រោះព្រះអង្គឡើងសោយរាជ្យចាប់ពីគ.ស.៦៥៧ ដល់ ៦៨១ ប៉ុណ្ណោះ។ ប៉ុន្តែ លោក ហ្សក សឺដេស មិនយល់ថាទ្រង់ជាព្រះបាទជ័យវម៌្មទី២នោះឡើយ ព្រោះលោកយល់ថាព្រះអង្គឡើងសោយរាជ្យពេញបរិបូណ៌នៅគ.ស.៨០២។ម្ល៉ោះហើយ ស្តេចដែលមានព្រះនាមថា "ជ័យវម៌្ម" ដែលស្ថិតនៅក្នុងព្រឹត្តិការណ៍មុនគ.ស.៨០២ លោកហៅថា "**ព្រះបាទជ័យវរ្ម័នទី១ស្ទួន**"។ តាមខ្លឹមសារសិលាចារឹកកំពូលតានន់នេះ បង្ហាញយ៉ាងច្បាស់ថា ព្រះបាទជ័យវរ្ម័នទី២ ជាអធិរាជ ពោល គឺមានន័យអាចបញ្ជាក់កស្តុតាងបន្ថែមថា ទ្រង់ជាស្តេចផែនដីពេញបរិបូណ៌រួចស្រេចទៅហើយនៅគ.ស.៧៦៣។ បន្ថែមពីនេះ តាមខ្លឹមសារសិលាចារឹកកំពូលតានន់ ទ្រង់ទំនងបានយាងទៅកាន់ទីក្រុងបុរាណ (គិរបាទ) ព្រោះយ៉ាងហោចណាស់តំបន់នេះគឺជាអតីតទីក្រុងដែលធ្លាប់មានមនុស្សរស់នៅតាំងពីរជ្ជកាលព្រះបាទគ្រីពៅទ្រវម៌្មមកម្ល៉េះ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

*សិលាចារឹកកំពូលតានន់ ឬដុបតាញៀន ជាបង្គោលថ្មកក់ដែលមានអក្សរចារឹកចំនួន ៣០ បន្ទាត់ ចារឹកជាភាសាសំស្ក្រឹតចំនួន ២១ បន្ទាត់ និងភាសាខ្មែរបុរាណចំនួន ៩ បន្ទាត់។ ខ្លឹមសារ និងអត្ថន័យជារួមរបស់សិលាចារឹកនេះ រៀបរាប់អំពីគុណតម្លៃ និងឫទ្ធានុភាពរបស់ព្រះសិវដោយអនេកាតិប្រាយជាច្រើនបែបយ៉ាង (ស្លោកទី១-៧) និងពណ៌នាព្រះបាទស្រីជយវម៌្ម (ទី២) គឺជាអធិរាជលើអស់បណ្ដាស្ដេចនានា (ស្លោកទី៨)។ ចាប់ពីស្លោកទី៩ ដល់ទី២០ គឺពណ៌នាអំពីគុណសម្បត្តិ និងភាពជាអ្នកដឹកនាំរបស់ព្រះបាទស្រីជយវម៌្ម (ទី២) ហើយស្លោកចុងក្រោយទី២១ រៀបរាប់អំពីការប្រតិស្ឋានប្រតិមា **ព្រះត្រៃលោកនាថ (ព្រះវិស្ណុ)** អំពីមាសនៅក្នុងមហាសករាជឆ្នាំ ៦៨៥ (ត្រូវនឹងគ.ស.៧៦៣)។*

## អត្ថបទចារឹក និងសេចក្ដីប្រែ

១. ............................. ......[ជា]ជគត្ថិហពហារះ
ប្រលយស្ថិតិសក្ត៌ាណាំ កាត្ត៌ាយះបរមេត្វរះ។

ប្រែថា៖ .......... *ភាពអន្តការនៃការកកើត ការស្ថិតនៅ និងការប្រល័យអស់ទៅ រមែងបន្សាត់បង់ទៅ ព្រះអាទិទេពអង្គណាជាអ្នកធ្វើ ព្រះអាទិទេពអង្គនោះជា **ព្រះបរមេត្វរ**។*

២. ................................ [ផ]លហាពេបិមង្គលះ
អយោនិវ៌្វិត្វយោនិយ៉្យោ វិគ្វេកត្វជិរីត្វរះ។

ប្រែថា៖ ..............*សូម្បីព្រះអង្គជាផលហារ (ពោល គឺជាអ្នកនាំយកផលទៅ) ក្ដី ក៏ទ្រង់នៅតែជាមង្គល, (សូម្បី) ព្រះអង្គជាអយោនី (ពោល គឺគ្មានទីប្រភព )ក្ដី, (ប៉ុន្តែ) ទ្រង់ជាវិត្វយោនី (ពោល គឺសព្វសារពើទាំងអស់ជាប្រភពរបស់ទ្រង់), ព្រះអង្គជាវិគ្វេក (ពោល គឺធំជាងគេលើសាកលលោក) ក្ដី (ប៉ុន្តែ) ទ្រង់ក៏ជាជិរីត្វរ (គិរីត្វរ គឺជាស្ដេចភ្នំ)។*

៣. ....................... ប្រត្យក្សត្វាប្យតីន្ទ្រិយះ
ជិទ្រាលុជាំតរុកាត្វ ត្វលចាណិន្ទ៌យាលយះ។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

AMS អរិយធម៌ខ្មែរ

*ប្រែថា៖ ................សូមរ្បីព្រះអង្គជាប្រត្យក្សៈ (ពោល គឺព្រះជាម្ចាស់ ឬមានព្រះនេត្រដែលប្រត្យក្សច្បាស់) ក្តី ទ្រង់ក៏ជាអតីន្ទ្រិយ (ពោល គឺអាត្មនដ៏ឧត្តុង្គឧត្តម ឬមិនមានឥន្ទ្រីយ៍អាចពាល់ត្រូវបាន), សូមរ្បីព្រះកំពុងផ្ទុំលង់លក់ក្តី ក៏ទ្រង់នៅតែមានស្មារតីភ្ញាក់រឭកខ្ពស់, សូមរ្បីព្រះអង្គជាគូលបាណិទ (មានត្រីសូលនៅនឹងព្រះហស្ត) កាន់នឹងព្រះហស្តក្តី ក៏ទ្រង់នៅតែជាទយាល័យ (ពោល គឺពោរពេញទៅដោយសេចក្តីអាណិតអាសូរ)។*

៤. ........................... យាយតីជាមិរពេត្តុរុះ
សមស្តេត្វយ៌្យយុក្តោបិ ក្វត្តិតសាត្វយស្សយមិ។

*ប្រែថា៖ ................. ព្រះអង្គជាគ្រូដ៏ប្រសើរនៃបព្វជិតទាំងឡាយ ព្រមទាំងប្រកបដោយឥស្សរយសគ្រប់យ៉ាង ចាប់តាំងពីការបានធ្វើដោយអំណាចរបស់ខ្លួន។*

៥. ................................. យំ វេទាន្តវិទោ វិទុះ
អាទិត្យវណ៌្ណមុទិតមិ បុរស្តាត្តមសស្សយមិ។

*ប្រែថា៖ ..............ព្រះអង្គជាអ្នកប្រាជ្ញលើវេទាន្តវិទូ (គឺពួកអ្នកប្រាជ្ញរៀនចប់គ្រប់សព្វខាងព្រះវេទទាំង៤) ប្រៀបដូចពណ៌នៃព្រះអាទិត្យដែលរះឡើងបំភ្លឺ ភាពងងឹតដែលនៅចំពោះមុខរបស់ខ្លួន។*

៦. ............................... មណិត្រិមរណាលិតមិ
បុជាតិកុរជំយស្យ ចាជាម្មុជវជតិច្យុតមិ។

*ប្រែថា៖ ..............ត្រូវបានកខ្វក់ដោយសេចក្តីមរណៈដ៏ស្រួចស្រាល់បំផុត ហើយរមែងជម្រះឱ្យបរិសុទ្ធនូវពិភពលោកនេះ ឱ្យច្យុតចាកពីភាពសៅហ្មងដោយព្រះបាទដែលដូចបទុមបុប្ផានៃព្រះអាទិទេពអង្គណា។*

៧. ............................. វិបត្តិកមជីជ្រិវមិ
ក្វតានមស្រ្តិយាយត្រែ សុខត្រិតយសាជជី។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

ប្រែថា៖ ............វិបត្តិទាំងពួងនឹងសាបសូន្យទៅយ៉ាងឆាប់រហ័ស នរជនជាអ្នកធ្វើកិច្ចនមស្ការក្នុងទីណារមែងជាអ្នកកើននូវសេចក្ដីសុខទាំងបីប្រការ (ធម៌ អថ៌ និងកាម) (ក្នុងទីនោះ)។

៨. .................[រា]ជរាជា រាជរាជសមច្យុតិះ
អស្តិ ត្រីជយវម៌្មេតិ រាជញ្យាច្ចិ៍តគាសនះ។

ប្រែថា៖ មានព្រះរាជាមួយព្រះអង្គព្រះនាមថាត្រីជយវម៌្ម (ទី២) .... ដែលជាព្រះរាជានៃព្រះរាជាទាំងឡាយ ទ្រង់មានភាពត្រចះត្រចង់ជាងព្រះរាជានៃព្រះរាជាទាំងពួង ព្រះរាជបញ្ជារបស់ទ្រង់ត្រូវបានគោរពខ្ជាប់ខ្ជួនដោយព្រះរាជាទាំងឡាយ។

៩. ...........ត្រវម៌្មយះ ប្រជារក្សណាឧក្សិណះ
ក្សីណាត្មគិល្វិមក្សោធោ ជិក្សុក្សោណីបតីត្វរះ។

ប្រែថា៖ ...........ត្រវម៌្មយះ ដែលទៀងត្រង់ប្រកបដោយគុណធម៌ក្នុងការរក្សារការពារប្រជារាស្ត្រដូចជាម្សៅថ្នាំព្យាបាលជំងឺក្នុងខ្លួនឱ្យអស់រលីងទៅ ទ្រង់ជាធំលើស្ដេចផែនដីទាំងឡាយគ្រប់ទិសានុទិស។

១០. [សវ៌្វេ]បក្សបក្សេមុ សមោយត្វាគុត្វក្សណោះ
វន្ធកក្សុះក្សិតេន្ទ្រាណា បុណ្ឌរីកក្សណោមមិ។

ប្រែថា៖ ............ក្នុងបក្សស្របគ្នា និងបក្សមិនស្របគ្នា [ទាំងឡាយ] ឱ្យមានដំណើរស្មើគ្នារហ័សរហួនប្រកបដោយថាមពល ទ្រង់ជារាជសីហ៍នៃព្រះនគរ ទ្រង់មានព្រះទ័យទុកដាក់រក្សាថែទាំ (សូម្បី) ប្រជាជនទន់ខ្សោយគ្រប់រូបក្រោមម្លប់ស្វេតច្ឆត្រ (ពោល គឺក្រោមអាណាចក្ររបស់ទ្រង់)។

១១. ធារ]កក្សិតិបក្សុណ្ណាមិ កាង្ក្សន្ធម៌្មបជក្រាមមិ
យោរញ្ជយតិក្សមាំជិត្យំ ក្សមាមិរហិតក្សមាមិ។

ប្រែថា៖ ដំណើរតាមមាគ៌ាស្វែងរកព្រះធម៌ តែងតែមានសេចក្ដីប្រាថ្នាជាប់តាម (ដូចដំណើរ) នៃស្ដេចនាគដែលដូចជាប្រថពី [ទ្រទ្រង់ព្រះពិស្ណុ] (ដូច្នោះ)។ ជនណាលេចធ្លោដោយ

សេចក្តីសន្តោសប្រណីជានិច្ច ជននោះដូចជា (ទទួលបាន) នូវការសន្តោសប្រណីដែលមានប្រយោជន៍លើលោកវិញដូច្នោះ។

១២. ...ក្សីណាមក្សុទ្រមិ យោររក្សជវិក្សតមិ
ទូល៌ត្សិប្តមបក្សាលៃ ល៌ក្សយាះក្សេមវ្ត៌វទ្ធយំ។

ប្រែថា៖ មិនល្អិតតូច ដែលមិនអន់ថយ.......... ព្រះអង្គបានរក្សាបានយ៉ាងប្រុងប្រយ័ត្ន ហើយបោះបង់បានដោយកម្រទោះបីត្រូវទ្រាំនឹងការប្រមាថមាក់ងាយទាំងឡាយ ហើយនាំមកនូវសេចក្តីសុខក្សេមក្សាន្តរហូតចម្រើនរុងរឿង។

១៣. [កល្ប]ទ្រុម ឥវានន្ត ផលពោប្យវិបល្វះ
កតីវកាន្តិនិលយោ នពោមោឝយលក្សិតះ។

ប្រែថា៖ ព្រះអង្គប្រៀបប្រដូចទៅ [ដើមកល្ប] ព្រឹក្សដែលសូម្បីឱ្យផ្លែជាអនន្តហើយ ក៏នៅតែមានស្លឹក ទ្រង់ដូចជាព្រះចន្ទ្រកាន្តី (គឺពន្លឺដួងព្រះចន្ទ្រា) ឮដំនកាល័យ ដែលរះឡើងដោយឥតសៅហ្មង។

១៤. [សស]ង្ខចក្រចាណិយោ្យ នារាយនឥវាបរះ
អាក្រាន្តកុវនាភោគោ នានវាន្តកពោនច។

ប្រែថា៖ ទ្រង់មានព្រះហស្តទាំងទ្វេប្រដាប់ដោយកងចក្រ [ព្រមទាំងសា]ង្ខ ហាក់បីដូចជាព្រះរូបស្នងមួយព្រះអង្គទៀតនៃព្រះនារាយណ៍ ជាអ្នកបរិបូណ៌ដោយភោគផលមានលើដែនដីដែលបានគ្រប់គ្រង ជាអ្នកឱ្យទានជាប្រក្រតីដោយគ្មានការបំអកឡុកឡើយ។

១៥. [ហ]ង្សរាជ ឥវានេក រាជហង្សនិមេវិតះ
នជាតុបក្សបាតីយះ សវ៌្វទាមានសប្រិយះ។

ប្រែថា៖ ព្រះអង្គហាក់បីដូចជា រាជ[ហ]ង្ស ដែលត្រូវបានចាំគាល់បម្រើយ៉ាងល្អដោយរាជហង្សដ៏ច្រើនអនេក ទ្រង់មិនមែនជាស្តេចបក្សពួកនិយម ហើយទ្រង់មានទឹកព្រះទ័យស្រស់ប្រិមប្រិយ៍គ្រប់កាលទាំងពួង។

អត្ថបទដោយ៖ កំ វណ្ណាក់ និងព្រះតេជគុណ អេង សុគន់

១៦. [អ]គីត្តិភ្ភិរមិតិ យមិ ឆិស្នេហាឆ្វនសញ្ចយះ
ត្ម្នាទុរុបសប៌ញ្ច កល្បវ្រក្សមិតិទ្វិជះ។

ប្រែថា៖ *ព្រះអង្គជាអ្នកឈ្នះទាំងស្រុង នូវកិត្តិនាម [មិនល្អ] នៃភាពជាបុរស នូវសេចក្តីស្អប់ខ្ពើម និងនូវពស់អាសិរពិសដ៏ឃោរឃៅដែលវាចេញពីចំណង់តណ្ហា ទ្រង់ជាអារ្យជនដ៏ប្រសើរ (ដូច) ជាដើមកល្បព្រឹក្ស។*

១៧. នោមោជាត្រយណីយញ្ចនិ ឧត្រៃហាយមនជ្យជះ
វ្យសនន្និកុសសំចិតិ ត្រិលោលញ្ញិរមន្យតះ។

ប្រែថា៖ *ព្រះអង្គជាស្តេចដែលមិនជាទីច្រកអាស្រ័យនៃទោសកំហុស ទ្រង់ជាទីកកើតដទៃមួយទៀតនៃសេចក្តីសង្រ្គោះដ៏រហ័ស ទ្រង់ជានិមិត្តរូបនៃការរះឡើងនៃការអស់ទៅនូវព្យសនកម្ម និងទ្រង់ជាតួអង្គដទៃម្នាក់ទៀតនៃការសម្រេចនូវសេចក្តីសុខទាំងបីប្រការ (គឺ ធម៌ អថ៌ និងកាម) អស់កាលជាដរាប។*

១៨. យេជាតិរាជចរិត ប្រក្សាលនមនេកាគះ
ស្វកុណៃះក្សីរកុន្ទេន តុមារវដៃះក្ខតមិ។

ប្រែថា៖ *ព្រោះហេតុដូចបានថ្វាថ្ងៃមកជាអាទិ៍នេះ ដែលរាជប្រវត្តិ (របស់ទ្រង់) មានភាពបរិសុទ្ធថ្លៃថ្នូរជាច្រើនអនេករាប់ប្រមាណមិនបាន ក៏ព្រោះគុណគឺសេចក្តីល្អជាច្រើន ក៏ព្រោះការប្រហារភាពស្មោកគ្រោកទាំងពួងដោយលំពែងរាជក្សីរកុន្ត (ដែលជាលំពែងនៃទឹកដោះ គឺអំណាចដែលនាំមកប្រយោជន៍ដ៏ប្រសើរថ្លៃថ្លា)។*

១៩. វិនក្វរមកាក្វតនិ និជនជម្មិរុទ្ធាជនំ
យកសិស្តិរមហាយ៌្យមាយ៌្យមិ ជនជុម្តមន្ទិលយនិ។

ប្រែថា៖ *(ទ្រង់)បានដាក់ច្បាស់នូវធម៌ដែលនាំមកនូវសេចក្តីស្ងាប់ ដែលមិនមានភាពទៀងទាត់ និងវិនាសទៅជាធម្មតា ដើម្បីកិត្តិយសស្ថិតស្ថេរ ដែលគេលួចយកទៅមិនបាន ដែលប្រសើរ និងទុកជាទីគោរពវន្ទាដល់ជនានុជន។*

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

២០. ត្រិវិម្តបមបិប្រកាម- សុខមន្វក្ខហ្នញ្យុះ
សជាតនមជាមញូ កិរមាប្តុមិច្ឆញ្យូជមិ។

ប្រែថា៖ *ហើយព្រះរាជាទ្រង់ក៏កំពុងប្រាថ្នាដើម្បីដល់នូវតិវបទ ជាទីនាំមកនូវសួគ៌ា ជាសេចក្តីសុខដ៏មហិមា (ជាមាគ៌ា) ដែលមនុស្សមិនងាយនឹងប្រកាន់យកបាន ជាសនាតនធម៌ និងគួរដល់ការសរសើរលើកតម្កើង។*

២១. ...ត្រីជយៃកជាថង្វាត្រិ- ដ្គដ្ករហេមសំសិក្តំ
ច្រាតិម្ពិបតិ........... កក្ត្យាវាណាម្តមង្កាកោ។ ៚

ប្រែថា៖ *(ព្រោះហេតុដូច្នេះហើយ ព្រះបដិមាទេព) ព្រះត្រីជយៃកនាថ ដែលត្រូវបានសិតយ៉ាងល្អហើយដោយមាស ៣២ ដុំ ទ្រង់បានប្រតិស្ឋានទុកហើយ..........ក្នុងឆ្នាំមហាសករាជដ៏មានឥទ្ធិពលកំណត់ដោយ បដ=៦អប្ត=៨ វាណា=៥= ៦៨៥។*

*សរុបជារួមមក សិលាចារឹកប្រាសាទកំពូលតានន់ ឬហៅថាដុបតាញៀន បានផ្តល់ព័ត៌មានជាច្រើនបញ្ជាក់ឱ្យដឹងអំពីសកម្មភាពព្រឹត្តិការណ៍នយោបាយ និងព្រះកិត្តិនាមដ៏ឧត្តុង្គឧត្តមរបស់ព្រះបាទស្រីជយវម៌្ម (ទី២)។ តាមកាលបរិច្ឆេទដូចដែលបានបញ្ជាក់នៅក្នុងសិលាចារឹក ព្រះអង្គបានឡើងសោយរាជ្យពេញបរិបូណ៌រួចមកហើយក្នុងមហាសករាជឆ្នាំ ៦៨៥ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៧៦៣ ពោល គឺផ្ទុយពីការកំណត់របស់លោក ហ្សក សឺដេស ដែលគិតថាទ្រង់ឡើងសោយរាជ្យនៅគ្រិស្តសករាជឆ្នាំ៨០២។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*



រូបលេខ១៖ សិលាចារឹកកំពូលតានន់ ឬដុបតាញៀន

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន់



រូបលេខ២៨៖ ក្រដាសផ្តិតសិលាចារឹកកំពូលតានន់ ឬដុបតាញៀន

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់